អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# ការិយាល័យសហចៅក្រមស៊ើបអង្កេត
# OFFICE OF THE CO-INVESTIGATING JUDGES

## សេចក្ដីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ (០០៤/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស)

ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១

ក្នុងរយៈកាលកន្លងមក ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានធ្វើការជូនដំណឹងដល់សាធារណជនអំពីទីតាំងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង ០០៤ នោះទេ ដោយហេតុថា ដោយខុសពីសំណុំរឿង ០០២ សំណុំរឿង ០០៤ មានវិមតិសង្ស័យជាក់ច្បាស់ថាតើជនសង្ស័យនៅក្នុងសំណុំរឿងនេះស្ថិតនៅក្នុងប្រភេទនៃ “អ្នកទទួលខុសត្រូវខ្ពស់បំផុត” ស្របតាមមាត្រា ២ ស្ដីអំពីសមត្ថកិច្ចយុត្តាធិការនៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែរ ឬយ៉ាងណា ។ ប្រសិនបើតុលាការមិនមានយុត្តាធិការទេ នោះវានឹងមិនមែនជារឿងសមស្របនោះឡើយក្នុងការដែលត្រូវជំរុញឲ្យមានការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី បន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលបានចំនួន ២០០ រួចមកហើយនៅក្នុងសំណុំរឿងនេះ ព្រោះថា ការណ៍នេះអាចនឹងបង្កើតឲ្យមានការរំពឹងទុក ឬក្ដីសង្ឃឹម ដែលនឹងមិនអាចសម្រេចបាននាពេលក្រោយតែប៉ុណ្ណោះ។

ទោះបីជាយ៉ាងនេះក្ដី ដោយយោងទៅលើហេតុដែលថា មានការកើនឡើងជាខ្លាំងនូវព័ត៌មានដែលមានលក្ខណៈជាការប៉ាន់ស្មាន និងភ័ន្តច្រឡំ ដែលបានចុះផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយនានា និងនៅលើគេហទំព័រមួយជាក់លាក់ យើងសូមធ្វើការផ្ដល់ជូននូវព័ត៌មានដូចខាងក្រោម ដោយនឹងមិនធ្វើឲ្យប៉ះពាល់ដល់បញ្ហាច្បាប់មួយចំនួនដែលនឹងត្រូវដោះស្រាយនៅក្នុងដីកាដំណោះស្រាយឡើយ៖

១. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីបីនៅក្នុងសំណុំរឿង ០០៤ រាប់បញ្ចូលនូវទីតាំងឧក្រិដ្ឋកម្ម និងអង្គហេតុឧក្រិដ្ឋកម្ម ដូចខាងក្រោម៖

**ក- ខេត្តកំពង់ចាម (ភូមិភាគកណ្ដាល)**

- មន្ទីរសន្តិសុខវត្តអូរត្រកួន ឃុំពាមជីកង ស្រុកកងមាស
- មន្ទីរសន្តិសុខវត្តបាធាយ ឃុំបាធាយ ស្រុកបាធាយ
- មន្ទីរសន្តិសុខមិត្តសុប (គរ) ឃុំគរ ស្រុកព្រៃឈរ
- មន្ទីរសន្តិសុខវត្តភ្នំប្រុស ឃុំក្រឡា និង ឃុំអំពិល ស្រុកកំពង់សៀម
- កន្លែងសម្លាប់មនុស្សគោកព្រីង ឃុំវិហារធំ ស្រុកកំពង់សៀម
- មន្ទីរសន្តិសុខចំការស្វាយចន្ទី ឃុំស្វាយទាប ស្រុកចំការលើ
- ការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ ស្រុកព្រៃឈរ
- ការប្រល័យពូជសាសន៍ជនជាតិចាមនៅខេត្តកំពង់ចាម

**ខ- ខេត្តកំពង់ធំ (ភូមិភាគកណ្ដាល)**

- មន្ទីរសន្តិសុខវត្តស្រង៉ែ ឃុំត្បែង ស្រុកកំពង់ស្វាយ
- គុក និងកន្លែងសម្លាប់មនុស្សនៅទួលតាផ្លុង ឃុំកំពង់ចិនជើង ស្រុកស្ទោង
- មន្ទីរសន្តិសុខវត្តកណ្ដាល ឃុំច្រនៀង ស្រុកបារាយណ៍
- មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក ឃុំបាល្ល័ង ស្រុកបារាយណ៍

**គ- ខេត្តពោធិ៍សាត់ (ភូមិភាគពាយ័ព្យ)**

- គុកលេខ៨ ឃុំស្យា ស្រុកកណ្ដៀង
- ទីតាំងសម្លាប់នៅទួលពោធិ៍ជ្រៃ ឃុំស្រែស្ដុក ស្រុកកណ្ដៀង

**ឃ- ខេត្តបាត់ដំបង (ភូមិភាគពាយ័ព្យ)**

- មន្ទីរសន្តិសុខវត្តគីរីរម្យ ឃុំភ្នំសំពៅ ស្រុកបាណន់
- ទីតាំងសម្លាប់នៅបន្ទាយអូតាក្រែ ឃុំត្រែង ស្រុករតនមណ្ឌល
- មន្ទីរសន្តិសុខបន្ទាយត្រែង ឃុំត្រែង ស្រុករតនមណ្ឌល
- មន្ទីរសន្តិសុខវត្តធម្មយុត ស្រុកមោងឫស្សី
- មន្ទីរសន្តិសុខវត្តកណ្តាលដែលស្ថិតនៅចំកណ្តាល ទីក្រុងបាត់ដំបង
- មន្ទីរសន្តិសុខវត្តសម្តេច ឃុំតាប៉ុន ស្រុកសង្កែ
- មន្ទីរសន្តិសុខវត្តពោធិ៍លង្ការ ឃុំកំពុងព្រៀង ស្រុកសង្កែ

**ង- ខេត្តបន្ទាយមានជ័យ (ភូមិភាគពាយ័ព្យ)**

- មន្ទីរសន្តិសុខវត្តបន្ទាយនាង ឃុំបន្ទាយនាង ស្រុកមង្គលបូរី
- ទីតាំងសម្លាប់នៅល្អាងភ្នំគួយយំ ឃុំអូរប្រាសាទ ស្រុកមង្គលបុរី
- ទីតាំងសម្លាប់នៅវត្តចំការខ្នុរ ឃុំអូរអំបិល ស្រុកស៊ីសុផុន
- មន្ទីរសន្តិសុខភ្នំទ្រយោង ស្រុកព្រះនេត្រព្រះ
- មន្ទីរសន្តិសុខភូមិចក្រី ឃុំជួប ស្រុកព្រះនេត្រព្រះ
- វត្តព្រះនេត្រព្រះ និងចំការតាឡឹង
- ទំនប់ត្រពាំងថ្ម ឃុំប៉ោយចារ ស្រុកភ្នំស្រុក
- ស្ពានស្រែង និងទំនប់ព្រៃរនាម ស្រុកព្រះនេត្រព្រះ

**ច- ខេត្តតាកែវ (ភូមិភាគនិរតី)**

- មន្ទីរសន្តិសុខវត្តប្រធាតុ ឃុំគោកព្រេច ស្រុកគិរីវង់

**ឆ- ការបោសសម្អាត**

- ការបោសសម្អាតនៅភូមិភាគកណ្ដាល
- ការបោសសម្អាតនៅភូមិភាគពាយ័ព្យ

ជនរងគ្រោះដែលមានបំណងដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវទាក់ទងជាមួយនឹងផ្នែកគាំពារជនរងគ្រោះនៃ អ.វ.ត.ក. ដែលពួកគេអាចនឹងទទួលបានទំរង់បែបបទ និងព័ត៌មានបន្ថែមនានាពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យនៃការទទួលយក ព្រមទាំងរយៈពេលកំណត់នៃការដាក់ពាក្យសុំជាដើម។

*អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)*
*ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ*
*ប្រអប់សំបុត្រ P.O. Box 71 រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។*

*ការិយាល័យប្រចាំនៅប្រជុំជនក្រុង៖*
*ផ្ទះលេខ ៦A ផ្លូវលេខ ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន*
*រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ: ០២៣ ២១៤ ២៩១ ឬ ០៩៧ ៧៤២ ៤២១៨*

*ការិយាល័យបើកធ្វើការចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាក ។*

២. ក្នុងករណីដែលវិសាលភាពនៃកិច្ចស៊ើបសួរលាតសន្ធឹងដល់ទីតាំងឧក្រិដ្ឋកម្មផ្សេងៗទៀត សាធារណជននឹងត្រូវបានជូនដំណឹងបន្ថែមដោយឡែកក្នុងពេលវេលាសមស្រប។

៣. នៅក្នុងដំណាក់កាលនេះនៃនីតិវិធី សហព្រះរាជអាជ្ញាមិនមានមូលដ្ឋានផ្លូវច្បាប់ក្នុងការជូនដំណឹងដល់សាធារណៈជនអំពីទីតាំងឧក្រិដ្ឋកម្មផ្សេងទៀតឡើយ ដូច្នេះមានតែព័ត៌មានដែលផ្ដល់ដោយសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះដែលមានលក្ខណៈត្រឹមត្រូវ ។

***